# ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ យុទ្ធសាស្ត្រជាត ស្តីពីសុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិឆ្នាំ ២០២៥-២០៣០ និងនិយាមបែបបទប្រតបត្ត សម្រាប់បង្ការការចម្លងមេរោគអេដស៍ ស្វាយ និងរលាកថ្លើមប្រភេទបេ ពីម្ដាយទៅកូន ក្នុងសេវាឯកជន

**បង្ហាញដោយ Ms. ស៊ាន ស៊ូចិត្រា**
ប្រធានកម្មវិធីជាតិ PMTCT
នៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក

# សេចក្តីផ្តើម

ទំនួលខុសត្រូវរបស់អ្នកផ្តល់សេវាឯកជន ក្នុងការថែទាំមុនសម្រាល (ANC) និងសម្រាល គឺ៖

១-កំណត់ស្ថានភាពមេរោគអេដស៍ មេរោគស្វាយ និងមេរោគរលាកថ្លើមប្រភេទបេ របស់អតិថិជនទាំងអស់

២-ផ្តល់ការប្រឹក្សា ធ្វើតេស្ត និងបញ្ជូនសមស្រប

៣-ប្រសិនបើមានលទ្ធភាពធ្វើបាន ផ្តល់ការថែទាំ ការព្យាបាល និងការបង្ការចំពោះមេរោគអេដស៍ មេរោគស្វាយ និងមេរោគរលាកថ្លើមប្រភេទបេ ក្នុងអំឡុងពេលមានផ្ទៃពោះ និងពេលសម្រាល ឬក្រោយសម្រាល ដល់ស្ត្រីមានផ្ទៃពោះ ដៃគូ និងទារកប្រឈមទាំងអស់។

៤-អ្នកផ្តល់សេវាឯកជន តម្រូវឱ្យរាយការណ៍ប្រចាំខែ

# ផ្នែកទី ១៖

# សេវាបង្ការការចម្លងមេរោគអេដស៍ ស្វាយ និងរលាកថ្លើមប្រភេទបេ ពីម្ដាយទៅកូន ក្នុងអំឡុងពេលថៃទាំមុនសម្រាល

(ANC)

# ក. ការកំណត់ស្ថានភាពមេរោគអេដស៍ មេរោគស្វាយ និងរលាកថ្លើមប្រភេទបេ

1. សួរស្ត្រីមានផ្ទៃពោះថាតើនាងបានដឹងថាមានផ្ទុកមេរោគអេដស៍ដែរឬទេ?

   ស្ត្រីដែលមានមេរោគអេដស៍វិជ្ជមាន មិនចាំបាច់ធ្វើតេស្តរកមេរោគអេដស៍ម្តងទៀតទេ

   ប៉ុន្តែពួកគេនៅតែត្រូវធ្វើតេស្តរករោគស្វាយ និងរលាកថ្លើមប្រភេទបេ អំឡុងពេលមានផ្ទៃពោះ

2. ប្រសិនបើនាងមិនដឹងថា មានផ្ទុកមេរោគអេដស៍ទេ សូមសួរថាតើនាងបានធ្វើតេស្តរកមេរោគអេដស៍ និងរោគស្វាយ និងរលាកថ្លើមប្រភេទបេ ក្នុងផ្ទៃពោះនេះដែរឬទេ?

ប្រសិនបើនាងមានកំណត់ត្រាបង្ហាញពីការធ្វើតេស្តរកមេរោគអេដស៍ រោគស្វាយ និងរលាកថ្លើមប្រភេទបេ ដែលបានធ្វើរួចហើយនៅក្នុងពេលមានផ្ទៃពោះនេះ សូមកត់ត្រាព័ត៌មាននៅក្នុងបញ្ជីរបស់អ្នក។

ប្រសិនបើនាងមិនទាន់ត្រូវបានធ្វើតេស្តក្នុងពេលមានផ្ទៃពោះនេះទេ នាងត្រូវការការប្រឹក្សាមុនពេលធ្វើតេស្ត ហើយគួរតែត្រូវបានផ្តល់ការធ្វើតេស្ត។

## ខ. ការប្រឹក្សាមុនការធ្វើតេស្តរកមេរោគអេដស៍ រោគស្វាយ និងរលាកថ្លើមប្រភេទបេ ៖

- ការធ្វើតេស្ត និងការប្រឹក្សាអំពីមេរោគអេដស៍ រោគស្វាយ និងរលាកថ្លើមប្រភេទបេ ចំពោះស្ត្រីមានផ្ទៃពោះគួរតែធ្វើឡើងដោយស្ម័គ្រចិត្ត និងប្រកាន់ខ្ជាប់នូវគោលការណ៍ទាំងប្រាំរបស់ WHO៖ ការយល់ព្រម ការរក្សាការសម្ងាត់ ការប្រឹក្សា លទ្ធផលតេស្តត្រឹមត្រូវ និងការភ្ជាប់សេវាថែទាំ ការព្យាបាល និងការការពារ។ សូមផ្តល់ចំពោះអតិថិជនទាំងអស់ដោយក្តីគោរព និងមេត្តា។ ធានាភាពឯកជនអំឡុងពេលផ្តល់ប្រឹក្សាក្រោយការធ្វើតេស្ត។

# គ. នីតិវិធីធ្វើតេស្តមេរោគអេដស៍/រោគស្វាយ និងរលាកថ្លើមប្រភេទបេ

- ការធ្វើតេស្តមេរោគអេដស៍ ស្វាយ និងរលាកថ្លើមប្រភេទបេ ត្រូវផ្តល់ជូនដល់ស្ត្រីមានផ្ទៃពោះនៅតាមទីកន្លែងផ្តល់សេវា ANC ទាំងអស់ តាមរយៈការធ្វើតេស្តរហ័សដោយដោះម្រាមដៃ គឺតេស្តមេរោគអេដស៍/មេរោគស្វាយរួមគ្នា (HIV/Syphilis dual test) និងតេស្ត HBsAg ដាច់ដោយឡែក។
- ការធ្វើតេស្តមេរោគអេដស៍ មេរោគស្វាយ និងរលាកថ្លើមប្រភេទបេ ត្រូវបានធ្វើឡើងដោយអ្នកផ្តល់សេវាដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវតែប៉ុណ្ណោះ។

# ឃ. ការប្រឹក្សាក្រោយការធ្វើតេស្ត ការបញ្ជូន និងការថែទាំ

**១.លទ្ធផលតេស្តអវិជ្ជមានសម្រាប់មេរោគអេដស៍ ស្វាយ និងរលាកថ្លើមប្រភេទបេ៖**

- ធានាថាអតិថិជនយល់ពី "រយៈពេលចំហ" ។
- ពិនិត្យឡើងវិញលើផែនការរបស់អតិថិជន ដើម្បីកាត់បន្ថយការប្រឈម
- ស្វែងយល់ទស្សនៈយល់ឃើញរបស់ស្ត្រី ចំពោះឥរិយាបថរបស់ប្តី ឬដៃគូ និងស្ថានភាពមេរោគអេដស៍ ស្វាយ និងរលាកថ្លើមប្រភេទបេ  និងកាមរោគរបស់គាត់។
- ប្រសិនបើស្ត្រីមានដៃគូដែលត្រូវបានគេដឹងថា មានផ្ទុកមេរោគអេដស៍ (ប្តីប្រពន្ធដែលមានលទ្ធផលតេស្តផ្ទុយគ្នា) នាងគួរតែត្រូវបានបញ្ជូនទៅទីតាំង ART ដើម្បីទទួលការប្រឹក្សា និងការព្យាបាលបង្ការដែលសមស្រប។
- ពន្យល់ពីគុណប្រយោជន៍ពីរមុខនៃការប្រើប្រាស់ស្រោមអនាម័យ ជាពិសេស សម្រាប់ស្ត្រីដែលគិតថា ប្តី ឬដៃគូរបស់ពួកគេអាចមានឥរិយាបថប្រឈមមុខខ្ពស់។
- ពន្យល់ពីសារៈសំខាន់នៃការផ្តល់ថ្នាំបង្ការ HBV ភ្លាមៗដល់ទារកទាំងអស់ក្នុងអំឡុងពេល ២៤ ម៉ោងក្រោយសម្រាល។
- ប្រាប់អតិថិជនថា ពួកគេអាចទទួលការប្រឹក្សាបន្ថែមទៀត ប្រសិនបើត្រូវការ។

## ៧.លទ្ធផលតេស្តមេរោគអេដស៍ប្រតិកម្ម

- ពិភាក្សាអត្ថន័យនៃលទ្ធផលតេស្ត និងយល់ពីអារម្មណ៍ដំបូងរបស់ពួកគេក្រោយពេលដឹងលទ្ធផល
- សង្កត់ធ្ងន់លើតម្រូវការដែលត្រូវធ្វើតេស្តបញ្ជាក់ក្នុងថ្ងៃតែមួយនៅទីតាំង *VCCT* ដែលស្ថិតនៅជាមួយគ្លីនិក *ART*
- បញ្ជាក់ពីដំណើរការបញ្ជូន និងបុគ្គលទំនាក់ទំនងនៅទីតាំងសេវាពាក់ព័ន្ធ
- បញ្ជូនអតិថិជនរួមជាមួយប័ណ្ណបញ្ជូន។
- ពិភាក្សាពីតម្រូវការសម្រាប់បន្តការថែទាំផ្ទៃពោះមុនពេលសម្រាលជាប្រចាំ, តេស្តផ្សេងៗទៀត និងវិធានការបង្ការ
- អ្នកផ្តល់សេវា ANC គួរតែតាមដានបន្ត និងធានាថា ស្ត្រីនោះបានទទួលការធ្វើតេស្តបញ្ជាក់ និងកត់ត្រាលទ្ធផលនៅក្នុងសៀវភៅកំណត់ត្រា ANC ។
- ស្ត្រីដែលត្រូវបានបញ្ជាក់ថាមានផ្ទុកមេរោគអេដស៍ គួរតែចុះឈ្មោះជាបន្ទាន់នៅសេវាART ហើយត្រូវបានណែនាំឱ្យធ្វើការសម្រាលនៅមន្ទីរពេទ្យដែលមានទីតាំងរួមជាមួយនឹងកន្លែង ART ។
- អ្នកសម្របសម្រួល OD/PHD PMTCT គួរតែត្រូវបានជូនដំណឹងភ្លាមៗអំពីករណីដែលមិនបានធ្វើតេស្តបញ្ជាក់ ឬមិនបានចុះឈ្មោះក្នុង ART ។

## *៣.លទ្ធផលតេស្តវិជ្ជមានមេរោគស្វាយ*

### ក) ការប្រឹក្សា៖

- ពន្យល់ថា រោគស្វាយដែលមិនបានព្យាបាលគឺមានគ្រោះថ្នាក់ខ្លាំងចំពោះស្ត្រី និងទារក ប៉ុន្តែជំងឺនេះអាចព្យាបាលបានយ៉ាងងាយ។
- សង្កត់ធ្ងន់លើតម្រូវការសម្រាប់ការព្យាបាលភ្លាមៗដើម្បីការពារទារក។
- ពន្យល់ពីតម្រូវការសម្រាប់ស្វាមី/ដៃគូរបស់នាងក្នុងការទទួលការព្យាបាលផងដែរ ដើម្បីជៀសវាងការឆ្លងមេរោគលើខ្លួននាង និងទារក។
- ណែនាំស្ត្រីដែលមានរោគស្វាយក្នុងពេលមានផ្ទៃពោះ មកសម្រាលនៅមន្ទីរពេទ្យរដ្ឋ ដើម្បីធានាបាននូវការពិនិត្យតាមដានទារកបានត្រឹមត្រូវ។

# ខ) ការព្យាបាល

- អ្នកផ្តល់សេវា ANC ឯកជនត្រូវបានលើកទឹកចិត្តឱ្យផ្តល់ការព្យាបាលភ្លាមៗសម្រាប់រោគស្វាយក្នុងពេលមានផ្ទៃពោះ ស្របតាមពិធីសារជាតិ និងធានាថា Benzathine Penicillin G ត្រូវមាននៅក្នុងស្តុកសម្រាប់គោលបំណងនេះ។
- ប្រសិនបើដោយសារហេតុផលណាមួយ ដែលពួកគេមិនអាចផ្តល់ការព្យាបាលបាន អ្នកផ្តល់សេវាឯកជនគួរតែបញ្ជូនស្ត្រី និងដៃគូរបស់គាត់ទៅកាន់គ្លីនិកសុខភាពគ្រួសារ (FHC) ឬមន្ទីរពេទ្យបង្អែករដ្ឋដែលនៅជិតបំផុត ហើយតាមដានដើម្បីធានាថា ពួកគេទទួលបានការព្យាបាល។
- អ្នកសម្របសម្រួល OD/PHD PMTCT គួរតែត្រូវបានជូនដំណឹងភ្លាមៗអំពីករណីណាមួយដែលបាត់បង់ក្នុងការតាមដាន ពោលគឺមិនបានទទួលការព្យាបាលពេញលេញ។

# ៤. លទ្ធផលតេស្ត HBsAg វិជ្ជមាន ៖

- ផ្តល់ប្រឹក្សាស្ត្រីដែលមាន *HBsAg វិជ្ជមាន* ៖ គាត់មាន HBV រ៉ាំរ៉ៃ ប៉ុន្តែត្រូវការការធ្វើតេស្តបន្ថែមទៀត ដើម្បីមើលថាតើមានហានិភ័យនៃការឆ្លងដល់ទារកដែរឬទេ។
- ណែនាំស្ត្រីឱ្យទៅមន្ទីរពេទ្យ ឬមន្ទីរពិសោធន៍ដែលមានសមត្ថភាពធ្វើបន្ទុកវីរុស (HBV DNA Viral Load) ឬតេស្តរហ័សសម្រាប់ *HBeAg*។
- ស្ត្រីត្រូវចាត់ទុកថាមានហានិភ័យខ្ពស់ក្នុងការចម្លងទៅកូន ហើយនឹងត្រូវផ្តល់ឱសថ ដើម្បីកាត់បន្ថយមេរោគក្នុងឈាម និងការពារទារក ប្រសិនបើ៖
  - បន្ទុកមេរោគ (VL)>200,000UI/ml ឬ
  - HBeAg វិជ្ជមាន
- **ក្នុងករណី មូលដ្ឋានសុខាភិបាល មិនអាចធ្វើតេស្ត HBeAg ឬ HBV DNA Viral Load ទេ តាមគោលការណ៍ណែនាំថ្មីរបស់ WHO, ស្ត្រីដែលមានHBsAg វិជ្ជមានទាំងអស់ស្ត្រីនឹងត្រូវផ្តល់ឱសថបង្ការការចម្លងទៅកូន។**

- ការព្យាបាលដោយថ្នាំប្រឆាំងវីរុសសម្រាប់ស្ត្រីមានផ្ទៃពោះ ដែលមានជំងឺរលាកថ្លើមប្រភេទបេព្រំរ៉ែ យោងតាមលក្ខណៈវិនិច្ឆ័យខាងលើ គឺ Tenofovir (TDF) 300 mg មួយដងក្នុងមួយថ្ងៃ។ ត្រូវផ្តល់ចាប់ពីត្រីមាសទី២ (លើសពីសប្តាហ៍ទី១២) **នៃគភ៌រហូតដល់ ៦សប្តាហ៍ ក្រោយពេលសម្រាលកូន។**
- ស្ត្រី HBsAg+ ទាំងអស់ត្រូវការការត្រួតពិនិត្យតាមកាលកំណត់សម្រាប់សុខភាពរបស់ពួកគេបន្ទាប់ពីការសម្រាល (ប្រហែលម្តងក្នុងមួយឆ្នាំ ឬឆាប់ជាងនេះប្រសិនបើពួកគេមានរោគសញ្ញាណាមួយ)។ ពួកគេគួរតែទៅមន្ទីរពេទ្យបង្អែក មន្ទីរពេទ្យខេត្ត ឬមន្ទីរពេទ្យជាតិដែលមានសេវានេះ។
- ពង្រឹងការប្រើថ្នាំ TDF ខ្ជាប់ខ្ជួន នៅពល់ ANC ជាបន្តបន្ទាប់។ ណែនាំឱ្យទៅសម្រាលនៅមន្ទីរពេទ្យប្រសិនបើអាច
- ផ្តល់វ៉ាក់សាំង HBV ដល់ទារកភ្លាមៗបន្ទាប់ពីកើត ក្នុងរយៈពេល 2 ម៉ោង សម្រាប់ម្តាយដែលវិជ្ជមាន HBsAg ទាំងអស់ ទោះបីជាមិនត្រូវបានចាត់ទុកថាមានហានិភ័យខ្ពស់ក៏ដោយ។ ណែនាំឱ្យទទួលវ៉ាក់សាំង HBV ៣លើកទៀតតាមការកំណត់។

# ផ្នែកទី ២៖

# សេវាបង្ការការចម្លងមេរោគអេដស៍ និងស្វាយពីម្ដាយទៅកូន

# ក្នុងអំឡុងពេលសម្រាល និងក្រោយសម្រាល៖

# ក. ការថែទាំពេលសម្រាល

## 1. កំណត់ស្ថានភាពមេរោគអេដស៍ និងរោគស្វាយ៖

- នៅពេលមកដល់គ្លីនិកសម្ភព សៀវភៅសុខភាពមាតារបស់ស្ត្រីគួរតែត្រូវបានពិនិត្យរកមើលលទ្ធផលនៃការធ្វើតេស្តមេរោគអេដស៍ និងរោគស្វាយដែលបានធ្វើឡើងអំឡុងពេល ANC ។
- ស្ត្រីដែលមិនដឹងស្ថានភាពមេរោគអេដស៍ និងរោគស្វាយ គួរតែត្រូវបានផ្តល់ការប្រឹក្សា និងធ្វើតេស្ត។ ប្រសិនបើស្ត្រីបានធ្វើតេស្តរួចហើយនៅសេវា ANC ប៉ុន្តែមិនបានយកសៀវភៅឬលទ្ធផលតេស្តមកទេ សុំឱ្យនាង ឬគ្រួសាររបស់នាងទៅយកលទ្ធផលតេស្ត ប្រសិនបើផ្ទះរបស់ពួកគេនៅជិត។ ប្រសិនបើ ANC ត្រូវបានផ្តល់ជូននៅកន្លែងរបស់អ្នក អ្នកក៏អាចស្វែងរកព័ត៌មានពីកំណត់ត្រារបស់អ្នកផងដែរ។

## 2. ការធ្វើតេស្តឈាមរកមេរោគអេដស៍ និងរោគស្វាយ៖

- ប្រសិនបើមិនអាចផ្ទៀងផ្ទាត់ស្ថានភាពរបស់ស្ត្រីបានទេ គឺចាំបាច់ត្រូវធ្វើតេស្តម្តងទៀត ដោយអនុវត្តតាមនីតិវិធីនៃការប្រឹក្សា និងការធ្វើតេស្តដែលបានរៀបរាប់នៅក្នុងផ្នែកទី១ខាងលើ។
  - ប្រសិនបើស្ត្រីកំពុងឈឺពោះសម្រាល ប៉ុន្តែមាត់ស្បូនបើកតិចជាង 4 សង់ទីម៉ែត្រ នាងគួរតែត្រូវបានធ្វើតេស្តមេរោគអេដស៍/ស្វាយ បន្ទាប់ពីទទួលបានការប្រឹក្សាដោយធ្មប ដោយមានការយល់ព្រមពីស្ត្រីផងដែរ។
  - ប្រសិនបើការសម្រាលកៀកខ្លាំងពេក(មាត់ស្បូនបើកធំជាង 4 សង់ទីម៉ែត្រ) ឬទារកបានកើតរួចហើយ ស្ត្រីគួរតែទទួលការប្រឹក្សា និងធ្វើតេស្តឱ្យបានឆាប់តាមដែលអាចធ្វើទៅបានបន្ទាប់ពីការសម្រាល។

## 2. ការធ្វើតេស្តឈាមរកមេរោគអេដស៍ និងរោគស្វាយ៖ (បន្ត)

- ប្រសិនបើលទ្ធផលតេស្តមានប្រតិកម្មចំពោះមេរោគអេដស៍ សូមពិចារណាបញ្ជូនទៅមន្ទីរពេទ្យរដ្ឋដែលមានទីតាំងរួមជាមួយនឹងគ្លីនិក ART ដើម្បីសម្រាលកូនសម្រាប់ការថែទាំត្រឹមត្រូវ

  (ART សម្រាប់ម្តាយ និងការបង្ការសម្រាប់ទារក ការធ្វើតេស្តទារក និងការតាមដាន)។

- ប្រសិនបើលទ្ធផលតេស្តមានប្រតិកម្មចំពោះមេរោគស្វាយ សូមធ្វើការព្យាបាលដូចបានរៀបរាប់ក្នុងផ្នែកទី១ ខាងលើហើយ ទារកត្រូវបានសន្មតថាមានជំងឺស្វាយពីកំណើត ដែលត្រូវការព្យាបាល ឬត្រូវបានបញ្ជូនទៅមន្ទីរពេទ្យខេត្ត ឬមន្ទីរពេទ្យជាតិ ដើម្បីព្យាបាលជំងឺស្វាយពីកំណើត។

## 3. ការសម្រាលកូនដោយសុវត្ថិភាពសម្រាប់ស្ត្រីដែលមានផ្ទុកមេរោគអេដស៍៖

- ការសម្រាលកូនតាមធម្មជាតិត្រូវបានណែនាំសម្រាប់ស្ត្រីមានផ្ទៃពោះដែលមានផ្ទុកមេរោគអេដស៍ទាំងអស់ ការសម្រាលកូនដោយវះកាត់មិនត្រូវបានណែនាំអនុវត្តជាប្រចាំទេ លើកលែងតែក្នុងករណីដែលមានល័ក្ខខ័ណ្ឌតម្រូវផ្នែកសម្ភពណាមួយ។ វិធានការខាងក្រោមនឹងជួយកាត់បន្ថយហានិភ័យនៃការចម្លងមេរោគអេដស៍ពីកំណើតទៅទារក៖
    - ជៀសវាងបំបែកទឹកភ្លោះដោយសិប្បនិម្មិត
    - ជៀសវាងការកាត់ទ្វារមាស
    - ជៀសវាងការជំរុញការឈឺពោះសម្រាល
    - កាត់បន្ថយការប្រើដង្កៀប ឬឧបករណ៍បូម
    - កាត់បន្ថយហានិភ័យនៃការធ្លាក់ឈាមក្រោយសម្រាល
    - អនុវត្តការប្រុងប្រយ័ត្នជាសកល

## 4. ធានាការផ្តល់ថ្នាំ ARVសម្រាប់ម្តាយដែលវិជ្ជមានមេរោគអេដស៍ និងទារកៈ

- ត្រូវកំណត់ថាតើស្រ្តីដែលវិជ្ជមានមេរោគអេដស៍បានប្រើថ្នាំ ARV រួចហើយឬនៅ ?
  - ស្រ្តីផ្ទុកមេរោគអេដស៍បានទទួលARTរួចហើយ: ប្រឹក្សាអំពីសារៈសំខាន់នៃការបន្ត ART
  - ស្រ្តីផ្ទុកមេរោគអេដស៍ មិនទាន់បានប្រើ ART៖ វាចាំបាច់ណាស់ដែលស្រ្តីត្រូវចាប់ផ្តើម ART ភ្លាមៗ ដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងមេរោគអេដស៍ទៅទារក
  - ករណីប្រតិកម្មមេរោគអេដស៍ថ្មីនៅពេលឈឺពោះសម្រាល និងសម្រាល៖ វាចាំបាច់ណាស់ដែលស្រ្តីត្រូវទទួលការធ្វើតេស្តបញ្ជាក់ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ហើយចាប់ផ្តើម ART ប្រសិនបើបញ្ជាក់ថាវិជ្ជមាន។ ប្រសិនបើមិនអាចធ្វើតេស្តបញ្ជាក់បានភ្លាមៗទេ នោះ ART គួរតែត្រូវបានចាប់ផ្តើមក្នុងពេលកំពុងរង់ចាំការធ្វើតេស្ត ហើយឈប់នៅពេលក្រោយ ប្រសិនបើការធ្វើតេស្តបញ្ជាក់អវិជ្ជមាន។

- ទារកដែលកើតពីម្ដាយវិជ្ជមានមេរោគអេដស៍ទាំងអស់ គួរទទួលបាន ARV សម្រាប់បង្ការ៖
  - ប្រសិនបើម្ដាយបានទទួល ART យ៉ាងហោចណាស់ 4 សប្ដាហ៍មុនពេលសម្រាល ទារកត្រូវការថ្នាំ Nevirapine 6 សប្ដាហ៍។
  - ប្រសិនបើម្ដាយបានទទួលART តិចជាង 4 សប្ដាហ៍ ទារកត្រូវការថ្នាំ Nevirapine 12 សប្ដាហ៍ និង AZT prophylaxis 6 សប្ដាហ៍។
- ប្រសិនបើសេវាឯកជនមិនអាចរកឱសថ ARV បានទេ សូមបញ្ជូនស្ត្រី (និងទារក)ទៅសេវាសម្ភពនៃមន្ទីរពេទ្យរដ្ឋ ដែលមានទីតាំងនៅរួមជាមួយនឹងគ្លីនិក ART សម្រាប់ការថែទាំសមស្រប។ ការបញ្ជូនអាចត្រូវបានធ្វើក្នុងអំឡុងពេលចាប់ផ្ដើមឈឺពោះដំបូង ឬភ្លាមៗបន្ទាប់ពីការសម្រាល។ ស្ត្រីគួរតែត្រូវបានអមដំណើរដោយឆ្មប ឬគ្រូពេទ្យអំឡុងពេលបញ្ជូន។

## 5. ធានាការព្យាបាលរោគស្វាយម្ដាយ និងរោគស្វាយពីកំណើត៖

- ស្ត្រីសម្រាលកូនដែលវិជ្ជមានមេរោគរោគស្វាយ កំណត់ត្រារបស់ម្ដាយ គួរតែត្រូវបានពិនិត្យរកភស្តុតាងនៃការព្យាបាល៖
- ប្រសិនបើម្ដាយ និង/ឬដៃគូរបស់គាត់មិនត្រូវបានព្យាបាលរោគស្វាយអំឡុងពេលមានផ្ទៃពោះនោះ ពួកគេត្រូវការការព្យាបាលឥឡូវនេះ ដូចដែលបានពិពណ៌នានៅក្នុងផ្នែកទី១។
- ប្រសិនបើម្ដាយបានទទួលថ្នាំ benzathine penicillin យ៉ាងហោចណាស់មួយដូសក្នុងពេលមានផ្ទៃពោះនោះ គ្មានការព្យាបាលណាមួយចាំបាច់សម្រាប់ទារកនោះទេ លុះត្រាតែមានរោគសញ្ញានៃរោគស្វាយពីកំណើត។

## 5. ធានាការព្យាបាលរោគស្វាយម្ដាយ និងរោគស្វាយពីកំណើត៖ (បន្ត)

- ប្រសិនបើម្ដាយមិនត្រូវបានព្យាបាលអំឡុងពេលមានផ្ទៃពោះ ឬព្យាបាលដោយថ្នាំផ្សេងក្រៅពីប៉េនីស៊ីលីន ឬព្យាបាលតិចជាង 30 ថ្ងៃមុនពេលសម្រាល នោះទារកក៏ត្រូវព្យាបាលរោគស្វាយពីកំណើតផងដែរ ទោះបីជាមិនមានរោគសញ្ញាក៏ដោយ។ ការព្យាបាលនេះតម្រូវឱ្យប្រើ Penicillin ចាក់តាមសរសៃ រយៈពេលវែង ដែលទារកគួរត្រូវបានបញ្ជូនទៅមន្ទីរពេទ្យកុមារថ្នាក់ខេត្ត ឬមន្ទីរពេទ្យជាតិ។ សេវាឯកជន ដែលមានឯកទេសផ្នែករោគកុមារ និងទារកទើបកើត អាចព្យាបាលរោគស្វាយពីកំណើត នេះផងដែរ ដោយអនុវត្តតាមគោលការណ៍ណែនាំជាតិ។

# ខ. ការថែទាំក្រោយការសម្រាល

- **ការប្រឹក្សាអំពីការបំបៅទារក៖**
  - ការបំបៅដោះ (BF) មានសុវត្ថិភាពនៅពេលដែលមេរោគក្នុងខ្លួនម្តាយមានកម្រិតទាប។ សូម្បីតែនៅពេលដែលមេរោគមានកម្រិតខ្ពស់ក៏ដោយ ក៏វាមានសុវត្ថិភាពជាងការចិញ្ចឹមចម្រុះ ឬបំបៅដោះគោម្សៅ ដែលបានផ្តល់ឱ្យមិនត្រឹមត្រូវ។
  - ម្តាយដែលទទូចឱ្យបំបៅដោះគោម្សៅ ត្រូវផ្តល់ការណែនាំច្បាស់លាស់៖ ទឹកដោះគោខាប់មិនមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ទេ។ ទឹកដោះគោម្សៅត្រូវតែរៀបចំដោយទឹកស្អាតមានសុវត្ថិភាព (ដប ឬដាំ) និងក្នុងការលាយត្រឹមត្រូវប៉ុណ្ណោះ។

## ខ. ការថែទាំក្រោយការសម្រាល (បន្ត)

- **ការប្រឹក្សា និងការបញ្ជូនបន្តសម្រាប់ការតាមដានទារក៖**
  - ទារកដែលប្រឈមមេរោគអេដស៍ទាំងអស់ត្រូវបញ្ជូនទៅកន្លែង ART សម្រាប់ការធ្វើតេស្តរោគវិនិច្ឆ័យ និងការការពារជំងឺឱកាសនិយម ។ ការពិនិត្យលើកដំបូងគួរតែឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីឱ្យ DNA-PCR អាចត្រូវបានធ្វើឡើងភ្លាមៗបន្ទាប់ពីកំណើត។
  - ប្រឹក្សាអំពីតម្រូវការសម្រាប់ការចាក់ថ្នាំបង្ការជាប្រចាំ

# គ. កូនស្លាប់កើតនិងការរលូតកូនដោយឯកឯង

- រោគស្វាយរបស់ម្តាយគឺជាមូលហេតុញឹកញាប់នៃការរលូតកូនដោយឯកឯងក្នុងត្រីមាសទី 2 និងកូនស្លាប់កើត។ ដូច្នេះ ស្ត្រីទាំងអស់ដែលត្រូវចូលមកដោយការរលូតកូនដោយឯកឯងដែលកើតឡើងក្រោយសប្តាហ៍ទី 20 ហើយស្ត្រីទាំងអស់ដែលកូនស្លាប់កើត ត្រូវតែពិនិត្យស្ថានភាពរោគស្វាយរបស់ពួកគេ។
- ប្រសិនបើស្ត្រីមិនត្រូវបានធ្វើតេស្តរករោគស្វាយក្នុងអំឡុងពេលមានផ្ទៃពោះទេនោះ ការធ្វើតេស្តគួរតែត្រូវបានផ្តល់ជូន។ ប្រសិនបើការធ្វើតេស្តមានប្រតិកម្ម ស្ត្រី និងដៃគូរបស់នាងគួរតែត្រូវបានព្យាបាលដូចដែលបានពិពណ៌នានៅក្នុងផ្នែកទី១ ខាងលើ ដើម្បីសុខភាពរបស់ពួកគេផ្ទាល់ និងដើម្បីការពារនៅពេលមានផ្ទៃពោះនាពេលអនាគត។

# ផ្នែកទីបី៖
# កំណាត់ត្រា និងច្បាយការណ៍

## ក. កំណត់ត្រា

- វិធានការសមស្របគួរតែត្រូវបានអនុវត្ត ដើម្បីធានាបាននូវការរក្សាទុកសម្ងាត់នៃកំណត់ត្រាទាំងនេះ។ សៀវភៅសុខភាពមាតា និងកំណត់ត្រារបស់អ្នកជំងឺ មកពិនិត្យផ្ទៃពោះ និងសម្រាល នៅសេវាឯកជនគួរកត់ត្រាព័ត៌មានឱ្យបានត្រឹមត្រូវ។

## ខ. របាយការណ៍ប្រចាំខែជូនក្រសួងសុខាភិបាល៖

- មូលដ្ឋានសុខាភិបាលឯកជន ដែលផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ ស្វាយ និងរលាកថ្លើមប្រភេទបេ ពីម្តាយទៅកូន ត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងសុខាភិបាល ដោយបំពេញព័ត៌មានដោយផ្ទាល់ទៅក្នុងប្រព័ន្ធទិន្នន័យ របស់កម្មវិធីជាតិបង្ការការចម្លងមេរោគអេស៍ ពីម្តាយទៅកូន នៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ( PMTCT Database ).
- មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក នឹងបូកសរុបរបាយការណ៍សម្រាប់ថ្នាក់ជាតិ ជូនក្រសួងសុខាភិបាល និងដៃគូពាក់ព័ន្ធ តាមការចាំបាច់។ មន្ត្រីទទួលបន្ទុក PMTCT/MCH នៃរាជធានី ខេត្ត និងស្រុកប្រតិបត្តិនីមួយៗ មានភារកិច្ចសម្របសម្រួល និងតាមដាន ដើម្បីធានាថារបាយការណ៍ពីមូលដ្ឋានសុខាភិបាលឯកជន នេះធ្វើឡើងដោយត្រឹមត្រូវ ពេញលេញ និងទាន់ពេលវេលា។

# សូមអរគុណ